**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៥៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារគ្រប់គ្រងកិច្ចការវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

---

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១.៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១.៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ លេខ ០៦ នស /០១.៩៦/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១.៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** បង្កើតក្រុមការងារគ្រប់គ្រងកិច្ចការវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ២:** ក្រុមការងារនេះមានសមាសភាពដូចតទៅៈ

១. លោក ប៊ុន បុណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ជាប្រធាន

២. លោក ស៊ុន ហេង អនុប្រធានការិយាល័យនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ សមាជិក

៣. លោក ម៉ម វិទ្ធី អនុប្រធានការិយាល័យនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ សមាជិក

**ប្រការ៣:** ក្រុមការងារនេះមានតួនាទី និងភារកិច្ចគ្រប់គ្រង និងជំរុញចំណូល និងបំណុលពីវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងការងារពាក់ព័ន្ធទៅនឹងវិស័យនេះក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ដូចប្រការ ៤
- កាលប្បវត្តិ និងឯកសារ